# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥ សសរ

## សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីអបអរសាទរការបញ្ចូល «តំបន់ប្រាសាទសំបូរព្រៃគុក» ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តនៃការគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-យោងសេចក្ដីសម្រេចDECISION 41 COM 8B. 15 ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧ ដែលបានសម្រេចចុះ "តំបន់ប្រាសាទសំបូរព្រៃគុក "ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

- យោងតាមការចាំបាច់។

## សម្រេច

**ប្រការ១៖** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីអបអរសាទរការបញ្ចូល «តំបន់ប្រាសាទសំបូរព្រៃគុក» ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលមានសមាសភាពដូចខាងក្រោម៖



www.pheakdeylaw.com

| | | |
|---|---|---|
| ១. លោកជំទាវ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២. ឯកឧត្តម **ហ៊ុន ម៉ានី** | ប្រធានស.ស.យ.ក | អនុប្រធាន |
| ៣. ឯកឧត្តម **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤. ឯកឧត្តម **ជុច ភឿន** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៥. ឯកឧត្តម **ជូ ខជិត្ត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៦. ឯកឧត្តម **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៧. ឯកឧត្តម **ជា ច័ន្ទបរិបូណ៌** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៨. លោកជំទាវ **ដាំ ដារីនី** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៩. លោកជំទាវ **ហ៊ុន ម៉ាណា** | អគ្គនាយិកាវិទ្យុ និងទូរទស្សន៍បាយ័ន | អនុប្រធាន |
| ១០. លោកជំទាវ **នេត្រ ភូម៉ារី** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១. ឯកឧត្តម **តុប សុភ័ក** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២. ឯកឧត្តម **សួខន ឬទ្ធិគុណា** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៣. លោកជំទាវ **ម៉ែន នារីសុភ័ក** | នាយកខុទ្ទកាល័យសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត | សមាជិក |
| ១៤. ឯកឧត្តម **ឌួខ អេលីត** | នាយកពិធីការកាកបាទក្រហមកម្ពុជា | សមាជិក |
| ១៥. ឯកឧត្តមឧត្តមសេនីយ៍ឯក **សរ មុន្នី** | បញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ១៦. ឯកឧត្តម **សុខ លូ** | អភិបាលនៃគណៈអភិបាលកំពង់ធំ | សមាជិកអចិន្ត្រៃយ៍ |
| ១៧. ឯកឧត្តម **ឈិន កេតនា** | អគ្គលេខាធិការនៃគណៈកម្មការបុណ្យជាតិអន្តរជាតិ | សមាជិក |
| ១៨. ឯកឧត្តម **ឆាន់ ណាឌី** | អគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក | សមាជិក |
| ១៩. ឯកឧត្តម **ឡុង ប៉ុណ្ណាស៊ីរីវឌ្ឍ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងវ.វ.សិ | សមាជិក |
| ២០. ឯកឧត្តម **ប្រាក់ សុណ្ណារ៉ា** | អគ្គនាយកបេតិកភណ្ឌ ក្រសួងវ.វ.សិ | សមាជិក |
| ២១. ឯកឧត្តម **ខ៉ាន់ ឆាលេរ៍** | តំណាងអគ្គនាយិកាវិទ្យុ និងទូរទស្សន៍បាយ័ន | សមាជិក |
| ២១. ឯកឧត្តម **និត្យ ថាវរិទ្ធ** | ប្រធានក្រុមបច្ចេកទេសទូរទស្សន៍បាយ័ន | សមាជិក |
| ២៣. លោកជំទាវ **សុទ្ធ សុម៉ាលី** | សមាជិកាគណៈកម្មការសិទ្ធិមនុស្សកម្ពុជា | សមាជិក |

**ប្រការ២៖** គណៈកម្មការអន្តរក្រសួងនេះមានតួនាទីដឹកនាំ និងសម្របសម្រួលរាល់ដំណើរការការងារ រៀបចំពិធីបួងសួងនៅ «តំបន់ប្រាសាទសំបូរព្រៃគុក» ដែលបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោក មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរដែនដី
- រៀបចំខ្លឹមសារ ឯកសារ លិខិតបទដ្ឋានរដ្ឋបាល បដាពាក្យស្លោក និងការងារពាក់ព័ន្ធសម្រាប់ពិធី
- រៀបចំគម្រោងចំណាយនៃកិច្ចដំណើរការរៀបចំពិធី
- រៀបចំពិធីក្រុងពាលី ពិធីបួងសួង និងពិធីកិច្ចសាសនាផ្សេងៗ
- ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់
- រៀបចំការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ ចរាចរ និងធានាសុវត្ថិភាពឲ្យបានគ្រប់គ្រាន់នៅមុន និងក្រោយពេលប្រារព្ធពិធី និងតាមផ្លូវឆ្លងកាត់
- ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវ

**ប្រការ៣៖** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែមតាមការ



www.pheakdeylaw.com

ចាំបាច់ ដោយមានការយល់ព្រម ពីប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៤៖** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គណៈកម្មការជាតិរៀបចំបុណ្យជាតិអន្តរជាតិ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ៤

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com